នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jun-2011, 14:32
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ជាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រម Jean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ អុតារ៉ា | |

| សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី: | មេធាវីការពារក្ដីជនជាប់ចោទ: | |
|---|---|---|
| ពេជ អង្គ | សុន អរុណ | ផាត់ ពៅសីាង |
| Elisabeth SIMONNEAU FORT | Michiel PESTMAN | Diana ELLIS QC |
| | Victor Koppe | ស សុវាន |
| | អាង ឧត្តម | Jacques VERGÈS |
| | Michael G.KARNAVAS | |

## ១. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ៩២ និង ៩៨.២ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា សូមដាក់ជូននូវ សារណា ដើម្បីគាំទ្រដល់សំណើរបស់ខ្លួន ដែលស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទឡើងវិញ ទាក់ទិននឹងអង្គហេតុនានាក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយកំណត់នូវអំពើរំលោភសេពសន្ថវៈ ជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"[1] នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## ២. ប្រវត្តិនៃនីតិវិធី

២. កថាខណ្ឌទី ១៦១៣ នៃដីកាដំណោះស្រាយ ដែលបានចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ បានចោទប្រកាន់ជនជាប់ចោទ ពីបទឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះរួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈផង[2]។ នៅក្នុងបណ្ដឹងឧទ្ធរណ៍ ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី និង អៀង ធីរិទ្ធ បានជំទាស់នឹងការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ដោយផ្អែកលើមូលដ្ឋានថា បទរំលោភសេពសន្ថវៈ គឺគ្មានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយដាច់ដោយឡែកដែលស្ថិតនៅក្រោមច្បាប់ទម្លាប់អន្តរជាតិនោះទេ ក្នុងអម្លុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩[3]។

៣. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីដែលប្រឆាំងនឹងដីកាដំណោះស្រាយ ហើយបានយល់ស្របតាមទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលថា "ការរំលោភសេពសន្ថវៈគ្មានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយក្នុង

---

[1] វិធានផ្ទៃក្នុងសម្រាប់ អវតក, វិសោធនកម្មលើកទី៧ , ចុះថ្ងៃទី ២៣ កុម្ភៈ ២០១១ [បន្ទាប់ទៅនេះហៅថា "វិធានផ្ទៃក្នុង អវតក"], វិធាន៩២, ៩៨.២ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់តាំងពីមុនហើយអំពីគោលបំណងរបស់ខ្លួនដែលចង់លើកឡើងពីបញ្ហានេះក្នុងពេលសវនាការបឋម។ *សូមអាន* សេចក្ដីជូន ដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបញ្ហាផ្នែកច្បាប់ទាំងឡាយដែលខ្លួនមានបំណងចង់លើកឡើងនៅក្នុងពេលសវនាការបឋម, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-អជសដ , ឯកសារលេខ E9/30, ថ្ងៃទី១៩ មេសា ២០១១, កថាខណ្ឌទី ១.៩(ខ) ។

[2] ដីកាដំណោះស្រាយ , ការិយាល័យសហចៅក្រមស៊ើបអង្កេត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស, ថ្ងៃទី ១៥ កញ្ញា ២០១០, ចាប់ពីពេលនេះទៅហៅថា "ដីកាដំណោះស្រាយ" កថាខណ្ឌទី ១៦១៣ ។

[3] បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស (អបជ ១៤៥), ឯកសារលេខ D427/2/1, ថ្ងៃទី១៨ តុលា ២០១០ ។ បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស (អបជ-៧៥), ឯកសារលេខ D427/1/6, ថ្ងៃទី២៥ តុលា ២០១០ ។

សិទ្ធិផ្ទាល់របស់ខ្លួននោះទេ ចាប់ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩"[4]។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះ បានលុបបទរំលោភសេពសន្ថវៈដែលថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចេញពីកថាខណ្ឌទី ១៦១៣.ឆ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5]។ ទោះជាយ៉ាងនេះក្តី ក៏អង្គបុរេជំនុំជម្រះ នៅតែបន្តធ្វើសេចក្តីសន្និដ្ឋានថាច្បាប់ទម្លាប់អន្តរជាតិ មិនបានហាមឃាត់មិនឱ្យកាត់ទោសលើបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងបទអំពើអមនុស្សធម៌ផ្សេងៗទៀតនោះឡើយ ហើយថា ហេតុដូចនេះ អង្គហេតុទាំងឡាយដែលត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងទម្រង់ជាការរំលោភសេពសន្ថវៈនោះ អាចឱ្យចាត់ចូលនៅក្នុងប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" បាន[6]។

៤. អង្គបុរេជំនុំជម្រះ បានពិនិត្យពិចារណាអំពីការរកឃើញនានាដែលបានលើកឡើងខាងលើ ទាក់ទងនឹង ការរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងសេចក្តីសម្រេចពេញលេញរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[7] ។

## ៣. សង្ខេបនៃអំណះអំណាង

៥. សហព្រះរាជអាជ្ញា សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង គួរតែច្រានចោលនូវការកំណត់បទចោទអំពីការប្រព្រឹត្តិបទរំលោភសេពសន្ថវៈ ដែលត្រូវបានអនុម័តយកដោយអង្គបុរេជំនុំជម្រះ ហើយត្រូវអនុវត្តនូវការកំណត់បទចោទដែលមានចែងនៅក្នុងដីកាដំណោះស្រាយដើមវិញ ដែលឆ្លុះបញ្ចាំងពី

[4] សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/ ១៩-០៩-២០០៧/អវតក-កសចស (អបជ-១៤៥និង អបជ-១៤៦), ឯកសារលេខ D427/2/12, ថ្ងៃទី១៣ មករា ២០១១, កថាខណ្ឌទី១១.២។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស (អបជ-៧៥), ឯកសារលេខ D427/1/26, ថ្ងៃទី ១៣ មករា ២០១១, កថាខណ្ឌទី ៧.២ ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស (អបជ-១០៤), ឯកសារលេខ D427/4/14, ថ្ងៃទី ១៣ មករា ២០១១, កថាខណ្ឌទី ២.២ ។

[5] *ដូចគ្នានឹងខាងលើ ។*

[6] *ដូចគ្នានឹងខាងលើ ។*

[7] សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/ ១៩-០៩-២០០៧-អវតក/កសចស (អបជ-១៤៥ និង ១៤៦), ឯកសារលេខ D427/2/12, D427/3/15 ចុះថ្ងៃទី ១៥ កុម្ភៈ ២០១១,កថាខណ្ឌទី ១៤៩-១៥៤។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-៧៥), ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ មេសា ២០១១, កថាខណ្ឌទី ៣៥៩-៣៧២។

ចរិតលក្ខណៈនៃការខូចខាតដែលបានបង្កឡើងជាក់លាក់ជាង។ ការកំណត់បទចោទលើអង្គហេតុពាក់ព័ន្ធនានារបស់សហចៅក្រមស៊ើបអង្កេត គឺជាការត្រឹមត្រូវ និង សមស្រប៖ មាត្រា៥ នៃច្បាប់ អវតក ចែងអំពីការកាត់ទោសពីបទរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្ទាល់តែម្តង ហើយការកំណត់បទចោទពីការប្រព្រឹត្តិបទរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដ៏ជាក់លាក់មួយ ដោយមិនចាត់ទុកថាជា "អំពើអមនុស្សធម៌" នោះ គឺស្របតាមគោលការណ៍ស្តីពីនីត្យានុកូលភាព។

៦. ការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែក គឺស្របទៅតាមគោលការណ៍ស្តីពីនីត្យានុកូលភាព ពីព្រោះទស្សនទាននៃបទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិមកទល់ត្រឹមឆ្នាំ១៩៧៥ ហើយដែលជនជាប់ចោទអាចឲ្យធ្វើការព្យាករណ៍ទុកជាមុនបាន និងអាចរកបានថា អំពើទាំងឡាយនៃការរំលោភសេពសន្ថវៈដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៧៥-១៩៧៩ គឺជាប្រធានបទដែលត្រូវធ្វើការផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែក ។

៧. លើសពីនេះ គឺគ្មានអ្វីជាមូលដ្ឋានដែលថាមិនត្រឹមត្រូវចំពោះការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈ ថាជា បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់មួយនោះទេ ដែលវាប្រសើរជាងថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទ "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ គោលការណ៍ស្តីពីនីត្យានុកូលភាព មិនបានតម្រូវឲ្យឧក្រិដ្ឋកម្មណាមួយដែលត្រូវបានប្រកាសហាមឃាត់ ដោយការប្រើពាក្យពេចន៍ជាក់លាក់ និងច្បាស់លាស់ ដែលក្រោយមកទៀតឧក្រិដ្ឋកម្មនេះ ត្រូវបានគេធ្វើការកាត់សេចក្តីនោះឡើយ ឲ្យតែជនជាប់ចោទអាចធ្វើការព្យាករណ៍ទុកជាមុនបាន និងដែលអាចរកបានយ៉ាងសមហេតុសមផលថា អំពើ ឬការធ្វេសប្រហែសជាក់លាក់មួយចំនួន តម្រូវជា ចាំបាច់ឲ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌតាមច្បាប់អន្តរជាតិ ។ ហេតុដូចនេះ គឺគ្មានអ្វីជា ឧបសគ្គរាំងដល់ការអនុវត្តមាត្រា៥ នៃច្បាប់ អវតក និងការកំណត់បទចោទផ្អែកតាម អង្គហេតុនានានៅក្នុងករណីនេះតាមករណីសមស្រប ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈ នោះឡើយ ។

៨. ជាចុងក្រោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គហេតុនានានៅក្នុងដីកាដំណោះស្រាយ ផ្តល់ជូននូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងរកឲ្យឃើញថា ការរំលោភសេពសន្ថវៈនៃ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតឡើងមែន ។ ជាពិសេស គេពុំចាំបាច់ពិនិត្យមើលអ្វីក្រៅពីវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ដោយហេតុថា អង្គហេតុនានាទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដូចគ្នាទៅនឹងអង្គហេតុទាំងឡាយទាក់ទិននឹងអំពើរំលោភសេពសន្ថវៈ ដូចដែលគេបានធ្វើចំណាត់ថ្នាក់បច្ចុប្បន្ននេះ មានន័យថា ជាអំពើអមនុស្សធម៌នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ។

## ៤. បញ្ហាជាចំបង

៩. ដោយសារជាបញ្ហាចំបង សហព្រះរាជអាជ្ញាកត់សំគាល់ថា សំណើរបស់ខ្លួន គឺជាការត្រឹមត្រូវដោយអនុលោមតាមវិធាន ៩៨(២) ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្លាស់ប្តូរនៅក្នុងសាលក្រមរបស់ខ្លួន អំពី "ការកំណត់បទចោទដូចបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"[8] ។ នៅក្នុងសំណុំរឿងលេខ ០០១ អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺថា ឃ្លា "មិនអាចបញ្ចូលធាតុផ្សំថ្មីនៃបទចោទ" គឺជាការបញ្ជាក់ឡើងវិញទៅលើឃ្លា "ការកំហិតដែលបានបង្កើតឡើងយ៉ាងច្បាស់ថា ការកំណត់បទចោទឡើងវិញណាមួយមិនត្រូវឲ្យហួសពីអង្គហេតុនានាដែលបានកំណត់នៅក្នុងឯកសារចោទប្រកាន់ឡើយ"[9] ។ សំណើរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការរំលោភសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនសម្ដីងទៅរកការបន្ថែមនូវព័ត៌មានទាក់ទិននឹងអង្គហេតុថ្មីទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ។ ផ្ទុយមកវិញ សំណើសុំធ្វើការកំណត់បទចោទឡើងវិញ គឺគ្រាន់តែមានការពាក់ព័ន្ធទៅនឹងការកែសម្រួលលើក្របខណ្ឌការងារ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ក្នុងការវាយតម្លៃលើអង្គហេតុនានាដែលមានរួចស្រេចហើយនៅចំពោះមុខតុលាការនេះតែប៉ុណ្ណោះ ។

[8] វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន ៩៨(២) ។

[9] សាលក្រមរបស់ អជសដ ចុះថ្ងៃទី ២៦ កក្កដា ២០១០, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, [ចាប់ពីនេះទៅហៅថា "សាលក្រមសំណុំរឿងលេខ ០០១"] កថាខ័ណ្ឌទី៤៩៤។ មេធាវីការពារក្តី អៀង សារី បានជូនជាយោបល់ឲ្យមានការកំហិតលើការបន្ថែម "ធាតុផ្សំសំខាន់ៗ" មិនមែនតែធាតុផ្សំអង្គហេតុទេ គឺរហូតដល់ធាតុផ្សំអង្គច្បាប់ផងដែរ។ *សូមអាន* សេចក្តីសង្កេតរបស់ អៀង សារី លើសេចក្តីជូនដំណឹងអំពីបញ្ហាច្បាប់របស់សហព្រះរាជអាជ្ញា ដែលខ្លួនបំណងចង់លើកឡើងនៅពេលសវនាការបឋម, អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ, E9/30/1, ចុះថ្ងៃទី ៣ ឧសភា ២០១១ [ចាប់ពីនេះតទៅហៅថា "សេចក្តីសង្កេតរបស់ អៀង សារី"], កថាខ័ណ្ឌទី១០ ។ គោលជំហរនេះ សាមញ្ញាយ៉ាងណាក៏មិនអាចជួយទ្រទ្រង់បានឡើយ ។ ដំណើរការនៃការផ្លាស់ប្តូរការកំណត់បទចោទចំពោះបទឧក្រិដ្ឋ តាមចរិតលក្ខណៈរបស់វា មានការពាក់ព័ន្ធក្នុងការកែសម្រួលធាតុផ្សំផ្លូវច្បាប់ ។ ការបកស្រាយណាមួយផ្សេងពីនេះលើវិធាន៩៨(២) នឹងធ្វើឲ្យបទប្បញ្ញត្តិមានលក្ខណៈច្រើនហួសហេតុ ។

១០. សហព្រះរាជអាជ្ញាទទួលស្គាល់ថា របៀបនៃការកំណត់បទចោទឡើងវិញអាចកើតឡើងបាន ត្រូវតែអនុវត្តទៅតាមសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ ដូចមានចែងកំណត់ក្នុងវិធាន៣៥ មានន័យថា ជនជាប់ចោទ "ត្រូវបានជូនដំណឹងទាន់ពេលវេលា និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន" និង "មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង"[10] ។ ករណីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលអនុវត្តបទដ្ឋានស្រដៀងគ្នានេះដែរ[11] បញ្ជាក់ថា ការកំណត់បទចោទឡើងវិញចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ត្រូវបានគេអនុញ្ញាតដរាបណាជនជាប់ចោទត្រូវបានប្រាប់ឲ្យដឹងអំពីលទ្ធភាពដែលថា ការកំណត់ខាងផ្លូវច្បាប់អំពីអង្គហេតុអាចត្រូវផ្លាស់ប្តូរ និងមានឱកាសរៀបចំការពារខ្លួនគាត់ស្របទៅតាមនោះ រួមទាំងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរនៅលើបញ្ហាដែលពាក់ព័ន្ធ[12] ។

១១. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនជាប់ចោទត្រូវបានជូនដំណឹងអំពីលទ្ធភាពដែលថា ការកំណត់ខាងផ្លូវច្បាប់អំពីអង្គហេតុនានាទាក់ទងនឹងការរំលោភសេពសន្ថវៈ អាចផ្លាស់ប្តូរពីអ្វីដូចមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានធ្វើវិសោធនកម្ម ។ ជនជាប់ចោទត្រូវបានប្រាប់ឲ្យដឹងតាម

---

[10] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ដោយមានការបញ្ចូលវិសោធនកម្មប្រកាសឲ្យប្រើនៅថ្ងៃទី២៧ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦), [ចាប់ពីនេះតទៅហៅថា "ច្បាប់ អ.វ.ត.ក"], មាត្រា ៣៥ ។

[11] *សូមអាន* អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប, មាត្រា៦(៣) ។

[12] *សូមអាន ជាឧទាហរណ៍ Pelissier និង Sassi ទល់នឹងប្រទេសបារាំង* [GC], 25444/94, ២៥ មីនា ១៩៩៩, កថាខ័ណ្ឌទី៤២, ៦២ (ដែលរកឃើញអំពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ប្រសិនបើនៅពេលមានការបន្ថែមបទចោទថ្មីនៃការជួយ និងទំនុកបម្រុង គឺជនជាប់ចោទមិនបានដឹង រហូតដល់ពេលមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ និងប្រសិនបើជនជាប់ចោទមិនមានឱកាសធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់លើបញ្ហាដែលពាក់ព័ន្ធ នៅខណៈដែលតុលាការឧទ្ធរណ៍កំពុងតែពិភាក្សា) ។ *Sipavicius ទល់នឹង Lithuania,* EctHR (no. 49094/99), ២១ កុម្ភៈ ២០០២, កថាខ័ណ្ឌទី២៦, ៣១-៣២ (មិនបានរកឃើញអំពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទទេ ទោះបីជាជនជាប់ចោទមិនបានរកឃើញរហូតដល់ពេលមានសាលក្រមដែលបទចោទប្រឆាំងនឹងរូបគាត់ត្រូវបានកំណត់ឡើងវិញ ដោយសារជនជាប់ចោទមានឱកាសនៅក្នុងអម្លុងពេលនៃដំណើរការសវនាការបណ្តឹងឧទ្ធរណ៍ដើម្បីឆ្លើយតបទៅនឹងបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធនានា និងការបង្កើនការការពារខ្លួនរបស់គាត់) ។ *I.H. និងដទៃទៀត ទល់នឹងប្រទេសអូទ្រីស* ECHR (លេខ 42780/98), ២០ មេសា ២០០៦, កថាខ័ណ្ឌទី៣៤ (ដែលរកឃើញអំពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ប្រសិនបើជនជាប់ចោទគ្មានសញ្ញាណបង្ហាញណាមួយឲ្យឃើញថា អង្គសវនាការអាចមានការសន្និដ្ឋានខុសគ្នាពីការចោទប្រកាន់ ទាក់ទិននឹងគុណវុឌ្ឍិនៃបទល្មើសណាមួយ និងថ្លែងថា "ដើម្បីឲ្យសិទ្ធិទទួលបាននូវការការពារខ្លួនអនុវត្តទៅបានប្រកបដោយប្រសិទ្ធិភាព មេធាវីការពារក្តីត្រូវតែមានព័ត៌មានពេញលេញ និងពិស្តារដែលអាចប្រើបានគ្រប់ពេលគ្រប់បំណងទាំងអស់របស់ខ្លួនទាក់ទិននឹងបទចោទដែលបានធ្វើឡើង រួមទាំងការកំណត់បទចោទដែលតុលាការអាចនឹងយកតាមលើបញ្ហានេះ ។ ព័ត៌មាននេះត្រូវផ្តល់ជូននៅមុនពេលសវនាការជំនុំជម្រះនៅក្នុងក្តីតាមលិខិតស្នើប្រកាសទោសជាផ្លូវការ ឬយ៉ាងហោចណាស់នៅក្នុងដំណើរការនៃសវនាការ តាមមធ្យោបាយផ្សេងៗដូចជា ការពង្រីកបទចោទជាផ្លូវការ ឬច្បាស់លាស់")។

រយៈដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានេះ ការបង្ហាញពីចេតនារបស់សហព្រះរាជអាជ្ញាកាលពីលើកមុនៗអំពីការចង់ស្វែងរកឲ្យមានការកំណត់បទចោទឡើងវិញ[13] និងការពិតដែលថា ការកំណត់បទចោទទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈ បានជូនដំណឹងម្ដងរួចហើយ តាមរយៈដីកាដំណោះស្រាយដើមមុនដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្ម ។ លើសពីនេះ ជនជាប់ចោទនឹងមានឱកាសដាក់ចេញនូវទស្សនៈរបស់ខ្លួននៅក្នុងចម្លើយតបរបស់ខ្លួន ទៅនឹងសំណើសុំធ្វើការកំណត់បទចោទឡើងវិញនេះ នៅពេលឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋាននេះ ។ ហេតុដូច្នេះ ការកំណត់បទចោទឡើងវិញណាមួយដែលអាចនឹងកើតមានឡើងនៅពេលប្រកាសសាលក្រម គឺពិតជាស្របទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ ។ ប៉ុន្តែ ដើម្បីជៀសវាងនូវភាពមិនប្រាកដប្រជាណាមួយ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចលើបញ្ហានេះមុនពេលចាប់ផ្ដើមសវនាការ ឬធ្វើការបញ្ជាក់ជាផ្លូវការថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើរបស់សហព្រះរាជអាជ្ញាទុកជាសេចក្ដីពិចារណាដោយប្រុងប្រយ័ត្ន ។

## **៥. អំណះអំណាង**

### **ក. បទរំលោភសេពសន្ថវៈត្រូវបានកំណត់នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែកមួយ នៅត្រឹមឆ្នាំ១៩៧៥**

១២. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ការបញ្ចូលបទរំលោភសេពសន្ថវៈ ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក គឺជាការឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ឡើងបន្តិចម្ដងៗ ពីការបញ្ចូលបទរំលោភសេពសន្ថវៈដែលមាននៅក្នុងប្រភពច្បាប់យោងនានា ដែលយ៉ាងហោចណាស់មានតាំងតែពី

[13] មេធាវីការពារក្ដីរបស់អៀង សារី ថ្មីៗនេះបានតវ៉ាថា សំណើសុំឲ្យកំណត់បទចោទជាថ្មីឡើងវិញរបស់សហព្រះរាជអាជ្ញា គឺជា "អញ្ញត្រកម្មបឋម" តាមវិធាន៨៩ នៃវិធានផ្ទៃក្នុង ដោយគេអះអាងថា សំណើទាំងនោះរួមបង្កើតបានជាអញ្ញត្រកម្មទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក។ *សូមអាន* ការសង្កេតរបស់ អៀង សារី ចំពោះសេចក្ដីជូនដំណឹងរបស់ សហព្រះរាជអាជ្ញាអំពីបញ្ហាដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម ។ ដែលសេចក្ដីសង្កេតនោះមានបំណងចង់លើកឡើងថា សវនាការបឋម [ត្រឹមត្រូវតាមច្បាប់ដើម], អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/ អបជ, ឯកសារលេខ E9/30/1, ចុះថ្ងៃទី៣ ឧសភា ២០១១ ។ នេះគឺមិនត្រឹមត្រូវឡើយ ។ ទីមួយគឺសហព្រះរាជអាជ្ញា មិនមាន "ជំទាស់" ទៅនឹងយុត្តាធិការរបស់ អវតក ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងនៅក្នុងច្បាប់ អវតក ទេ ដែលរួមបង្កើតបានជាចំណុចពាក់ព័ន្ធនានានៃសេចក្ដីយោង ។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងមិនបានចាត់ទុកសំណើប្រភេទនេះជា អញ្ញត្រកម្មតាមវិធាន៨៩ ទេ ពីមុនមក ។ *សូមអាន,* សាលក្រមនៃសំណុំរឿងលេខ០០១ កថាខណ្ឌទី ១៤ និងទី៤៨៩ (ដែលក្នុងនោះ គេអាចទាញជាសេចក្ដីស្និដ្ឋានបានថា សំណើរបស់សហព្រះរាជអាជ្ញា នៅក្នុងពេលសវនាបឋមដែលសុំឲ្យអនុវត្តនូវសហកម្មឧក្រិដ្ឋកម្មរួម អនុលោមតាមវិធាន៩៨.២នោះ មិនត្រូវចាត់ទុកថាជាអញ្ញត្រកម្មទេ ព្រោះអង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា "គ្មានអញ្ញត្រកម្មបឋម ទៅនឹងយុត្តាធិការរបស់ អវតក" ដែលត្រូវបានលើកឡើងនៅក្នុងសវនាការបឋមឡើយ) ។

សតវត្សរ៍ទី១៩ មកម្ល៉េះ។ ប្រភពច្បាប់យោងទាំងនេះ រួមមាន ប្រភពនានានៃច្បាប់មនុស្សធម៌អន្តរជាតិដែលបានលើកយកមកសំអាងដោយ អង្គបុរេជំនុំជម្រះ[14] គឺមាត្រា៤៤ នៃក្រម Lieber ឆ្នាំ១៨៦៣[15], បទបញ្ញានានាដែលជាឧបសម្ព័ន្ធនៃអនុសញ្ញានៃទីក្រុងឡាអេ[16] ។ អានភ្ជាប់ជាមួយនឹងបទប្បញ្ញត្តិរបស់ Martens ដែលចែងនៅក្នុងអារម្ភកថានៃអនុសញ្ញានោះ[17], អនុសញ្ញានានានៃទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[18], ពិធីសារបន្ថែមលើកទីI ឆ្នាំ១៩៧៧[19], និង ពិធីសារបន្ថែមលើកទីII ឆ្នាំ១៩៧៧[20]។

១៣. មានប្រភពផ្សេងៗទៀត បានបញ្ជាក់ភស្តុតាងបន្ថែមអំពីការរួមបញ្ចូលបន្តិចម្តងៗ ចំពោះបទរំលោភសេពសន្ថវៈនៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ។ ក្នុងឆ្នាំ១៩១៩ គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកដែលបង្កើតឱ្យមានសង្គ្រាម និងស្តីពីការអនុវត្តទោសបញ្ញត្តិដែលបានបង្កើតឡើងដោយរដ្ឋាភិបាលនានានៃបណ្តាប្រទេសជាសម្ព័ន្ធមិត្ត ដែលបានអំពាវនាវឱ្យបង្កើតតុលាការមួយដើម្បីធ្វើការជំនុំជម្រះលើជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងច្បាប់ និង

[14] *សូមអាន* សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ១៥១ ។

[15] សេចក្តីណែនាំសម្រាប់ការគ្រប់គ្រងកងទ័ពនៃសហរដ្ឋអាមេរិកនៅតាមមូលដ្ឋាននានា (ក្រម Lieber), ថ្ងៃទី២៤ មេសា ១៨៦៣, មាត្រា៤៤ ("រាល់អំពើហិង្សាដោយគ្មានធម៌មេត្តាទាំងអស់ ដែលបានប្រព្រឹត្តប្រឆាំងនឹងមនុស្សទាំងឡាយក្នុងប្រទេសដែលត្រូវបានគេចូលលុកលុយ [...] រាល់ការរំលោភសេពសន្ថវៈ, ការរងរបួស, ការធ្វើឱ្យមានពិការភាព ឬការសម្លាប់ប្រជាជនដែលជាអ្នកស្រុកនោះ ត្រូវបានហាមឃាត់ ដោយត្រូវមានទោសប្រហារជីវិត ឬ ការផ្តន្ទាទោសជាទម្ងន់ តាមការដែលអាចយល់ឃើញថាគ្រប់គ្រាន់ទៅតាមទម្ងន់ទោសនៃបទល្មើស") ។

[16] បទបញ្ញានានានៃទីក្រុងឡាអេ ទាក់ទងនឹងច្បាប់ស្តីពីសង្គ្រាមលើដីគោក ដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងអនុសញ្ញា (ទី៤) ស្តីពីការការពារជនស៊ីវិលនៅក្នុងពេលសង្គ្រាម, ឯកសារលេខ 75 U.N.T.S. 287, ថ្ងៃទី១២ សីហា ១៩៤៩, មាត្រា៤៦ ("អំពីកិត្តិយស និងសិទ្ធិរបស់គ្រួសារ, ជីវិតរបស់បុគ្គល និងទ្រព្យសម្បត្តិរបស់ឯកជន ក៏ដូចជា ជំនឿ និងការអនុវត្តខាងសាសនា ដែលត្រូវតែគោរព ") ។

[17] អនុសញ្ញាទី២នៃទីក្រុងឡាអេ, អារម្ភកថា ។

[18] អនុសញ្ញាទី៤ នៃទីក្រុងឡាអេ, មាត្រា២៧.២ ("ស្ត្រីត្រូវតែទទួលបាននូវការការពារជាពិសេសប្រឆាំងនឹងការវាយប្រហារណាមួយទៅលើកិត្តិយស ជាពិសេសប្រឆាំងនឹងអំពើរំលោភសេពសន្ថវៈ, ការបង្ខំឱ្យធ្វើពេស្យាចារ ឬការបៀតបៀនខាងផ្លូវភេទតាមទម្រង់ណាមួយ") ។

[19] ពិធីសារបន្ថែមទី១ ឆ្នាំ១៩៧៧, មាត្រា៧៦.១ (ដែលត្រូវបានអនុម័តដោយសម្លេងយល់ព្រមជាឯកច្ឆ័ន្ទ) ("ស្ត្រីគឺជាកម្មវត្ថុដែលត្រូវមានការគោរពជាពិសេស ហើយដែលត្រូវតែបានទទួលនូវការការពារ ជាពិសេសប្រឆាំងនឹងអំពើរំលោភសេពសន្ថវៈ, ការបង្ខំឱ្យធ្វើពេស្យាចារ ឬការបៀតបៀនកេរ្តិ៍ខ្មាស តាមទម្រង់ណាមួយ") ។

[20] ពិធីសារបន្ថែមទី២, មាត្រា៤.២.ង (ដែលត្រូវបានអនុម័តដោយសម្លេងយល់ព្រមជាឯកច្ឆ័ន្ទ) ("...អំពើទាំងឡាយដូចខាងក្រោមនេះដែលប្រឆាំងនឹង [បុគ្គលគ្រប់រូបទាំងអស់ដែលបានឈប់ចូលរួមចំណែកនៅក្នុងអំពើអរិភាព] គឺត្រូវបានហាមឃាត់ និងត្រូវស្ថិតនៅក្នុងការហាមឃាត់ដដែល នៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែងទាំងអស់ មិនថាពេលណា ឬទីកន្លែងណាឡើយ...(ង) អំពើសាហាវព្រៃផ្សៃទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេសការធ្វើឱ្យអាប់ឱន ឬប្រព្រឹត្តកម្មបន្ទាបបន្ថោកអំពើរំលោភសេពសន្ថវៈ, ការបង្ខំឱ្យធ្វើពេស្យាចារ ឬការបៀតបៀនកេរ្តិ៍ខ្មាស តាមទម្រង់ណាមួយ") ។

ទម្លាប់ ស្តីពីសង្គ្រាម ឬច្បាប់មនុស្សធម៌ ដោយរួមទាំង បទរំលោភសេពសន្ថវៈផង[21]។ តាមការពិត បទរំលោភសេពសន្ថវៈ មានចុះនៅក្នុងបញ្ជីនៅលំដាប់លេខរៀងទី៥ ក្នុងចំណោមបទចោទចំនួន ៣២ ដែលគណៈកម្មការបានរៀបរាប់ឈ្មោះស្នើឡើង[22] ។ ទោះបីជាតុលាការដែលត្រូវបានគិតទុកដោយគណៈកម្មការ ថាមិនដែលមានអត្ថិភាពជាក់ស្តែងទាល់តែសោះ នោះក៏ដោយក៏ការដាក់បញ្ចូលនូវបទរំលោភសេពសន្ថវៈនៅក្នុងចំណោមបទចោទនានាដែលបានស្នើឡើង បានផ្តល់នូវភស្តុតាងអំពីការឆ្លុះបញ្ចាំងឱ្យឃើញច្បាស់បន្តិចម្តងៗថា បទរំលោភសេពសន្ថវៈ គឺជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

១៤. បន្ទាប់មក នៅឆ្នាំ១៩៤៥ បទរំលោភសេពសន្ថវៈ ត្រូវបានគេរៀបរាប់ឈ្មោះយ៉ាងច្បាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ នៅក្នុងច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ("CCL10")[23]។ CCL10 គឺជាច្បាប់ដែលបានប្រកាសឱ្យប្រើដោយបណ្តាប្រទេសនៃសម្ព័ន្ធមិត្តសម្រាប់ធ្វើការជំនុំជម្រះក្តីលើពួកឧក្រិដ្ឋជនសង្គ្រាម នៃបណ្តាប្រទេសខាងបក្សសម្ព័ន្ធយោធា ក្រៅពី ឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗមួយចំនួនតូចចេញ ដែលត្រូវបានជំនុំជម្រះក្តីដោយតុលាការសឹកអន្តរជាតិ។ ច្បាប់នេះត្រូវបានអង្គបុរេជំនុំជម្រះ រៀបរាប់ថាជាច្បាប់របស់អង្គការនីតិបញ្ញត្តិ "ដែលឆ្លុះបញ្ចាំងកិច្ចព្រមព្រៀងអន្តរជាតិក្នុងចំណោមប្រទេសមហាអំណាចនានា លើច្បាប់ជាធរមានសម្រាប់អនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងលើយុត្តាធិការរបស់តុលាការសឹកអន្តរជាតិនានាដែលបានអំពាវនាវដើម្បីធ្វើការសម្រេចក្តីលើឧក្រិដ្ឋកម្មទាំងនេះ"[24]។ មាត្រា២ នៃច្បាប់ CCL10 បានយោងយ៉ាងជាក់លាក់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈ ដោយបានកំណត់និយមន័យនៃឧក្រិដ្ឋកម្ម

---

[21] របាយការណ៍របស់គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កើតសង្គ្រាម និងស្តីពីការពង្រឹងការអនុវត្តនូវទោសបញ្ញត្តិ, ថ្ងៃទី២៩ មីនា ១៩១៩, ត្រង់ទំព័រ ១៧ ។ តុលាការដែលបានគិតទុកជាមុនមិនដែលមាន អត្ថិភាពជាក់ស្តែងទាល់តែសោះ ដោយសារលទ្ធផលមកពីការគ្មានឆន្ទៈខាងនយោបាយដើម្បីធ្វើការកាត់ទោស ។

[22] *ក្នុងឯកសារដដែលដូចខាងលើ ។*

[23] ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០, ការផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយដែលត្រូវបានកាត់ឱ្យមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី២០ ធ្នូ ១៩៤៥, មាត្រា II.២.គ, *ដែលបានបោះពុម្ពឡើងវិញនៅក្នុងសវនាការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការសឹកនាទីក្រុងនូរឹមប៊ែរ ក្រោមច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០* (ក្បាលទី១) [បន្ទាប់ទៅនេះហៅថា "ច្បាប់ CCL 10"], ទំព័រ ១៦-១៧ ។

[24] *សូមអាន* សាលដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហកម្មឧក្រិដ្ឋកម្មរួម (JCE), សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស (អបជ ៣៨ ), ឯកសារលេខ D97/15/9, ចុះថ្ងៃទី២០ ឧសភា ២០១០, កថាខណ្ឌទី ៥៧។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ករណី *Prosecutor v. Kupreskic*, IT-95-16-A, ICTY, ចុះថ្ងៃទី ១៤ មករា ២០០០, កថាខណ្ឌទី ៥៤១ (បញ្ជាក់ថា ច្បាប់ CCL10 ជាលិខិតុបករណ៍មួយក្នុងចំណោមលិខិតុបករណ៍អន្តរជាតិនានា "ដែលបានដាក់ចេញនូវបញ្ញត្តិជាច្រើនដែលមានការប្រកាសច្បាប់ដែលមានស្រាប់ ឬដែលមានការកែប្រែជាបណ្តើរៗទៅជា ច្បាប់ទំលាប់អន្តរជាតិ"។

ប្រឆាំងនឹងមនុស្សជាតិ ថាជា៖"អំពើដ៏សហាវព្រៃផ្សៃ និងជាបទល្មើសដែលរួមបញ្ចូលតែមិនកំរិតត្រឹមតែ អំពើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឲ្យទៅជាទាសករ, ការនិរទេស, ការដាក់នៅក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភសេពសន្ថវៈ, ឬ អំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានប្រព្រឹត្តទៅលើប្រជាជនស៊ីវិលណាមួយ ឬ ការធ្វើទុក្ខបុកម្នេញផ្សេងៗដោយសារមូលហេតុខាងនយោបាយ ពូជសាសន៍ ឬ សាសនា ដែលបំពាន ឬមិនបំពានលើច្បាប់ក្នុងស្រុករបស់ប្រទេសដែលជាកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ប៉ុណ្ណោះនោះទេ"[25] ។

១៥. នៅពេលដែលច្បាប់ CCL 10 បានចែងច្បាស់ដោយចាត់ទុកថា បទរំលោភសេពសន្ថវៈ គឺជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ សហព្រះរាជអាជ្ញា ទទួលស្គាល់ថា ធម្មនុញ្ញរបស់តុលាការចំនួនពីរដែលត្រូវបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទីពីរ ដើម្បីជំនុំជម្រះក្តីលើពួកចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរជាងគេបំផុត - *គឺតុលាការសឹកអន្តរជាតិនៅទីក្រុងនូរឹមប៊ែរ និងតុលាការសឹកអន្តរជាតិសម្រាប់ចុងបូព៌ា* - មិនបានចែងអំពីសេចក្តីយោងជាក់លាក់ទៅលើ បទរំលោភសេពសន្ថវៈ ដាច់ដោយឡែកពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[26]។ ផ្ទុយទៅវិញ ដូចដែលអង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានទទួលស្គាល់រួចហើយថា ធម្មនុញ្ញរបស់តុលាការទាំងនោះ បានរួមបញ្ចូលនូវបទរំលោភសេពសន្ថវៈ ដែលស្ថិតនៅក្រោមចំណងជើងថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទ "អំពើអមុនស្សធម៌ផ្សេងៗទៀត"[27]។ ទោះជាយ៉ាងណាក្តីភស្តុតាងអំពី បទរំលោភសេពសន្ថវៈ *ត្រូវបាន* បង្ហាញជូនដោយរដ្ឋអាជ្ញានានានៅទីក្រុងនូរឹមប៊ែរ[28] ហើយនៅពេលដែលសាលក្រមតុលាការទីក្រុងនូរឹមប៊ែរ មិនបានផ្តល់នូវការយកចិត្តទុកដាក់ច្បាស់លាស់ទៅលើភស្តុតាងនេះ និងផ្ទុយទៅវិញ គ្មានចុងចោទណាម្នាក់ក្នុងចំណោមចុងចោទទាំងអស់ត្រូវបានកាត់ឲ្យជាប់ទោសពីបទរំលោភសេពសន្ថវៈ ក្នុងលក្ខខណ្ឌជាក់លាក់នោះ គឺហាក់បីដូចជាថា

[25] ច្បាប់ CCL 10, កថាខណ្ឌទី ១៦-១៧ ។ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*)

[26] កិច្ចព្រមព្រៀងក្នុងការកាត់ទោស និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃបណ្តាប្រទេសមហាអំណាចនៅក្នុងបក្សសម្ព័ន្ធយោធានៃទ្វីបអឺរ៉ុប និងធម្មនុញ្ញនៃតុលាការសឹកអន្តរជាតិ, ថ្ងៃទី៨ សីហា ១៩៤៥, ឯកសារលេខ ៨២ U.N.T.S. 279, មាត្រា ៦.គ ។ ធម្មនុញ្ញនៃតុលាការសឹកអន្តរជាតិសំរាប់ចុងបូព៌ា, ដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីប្រកាសពិសេស, ថ្ងៃទី១៩ មករា ១៩៤៦ ដែលធ្វើឡើងដោយអគ្គមេបញ្ជាការនៃបណ្តាប្រទេសមហាអំណាចរបស់សម្ព័ន្ធមិត្តនៅចុងបូព៌ា, មាត្រា៥.គ ។

[27] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, ឯកសារលេខ E១៨៨ [សាលក្រមសំណុំរឿង ០០១] កថាខណ្ឌទី ២៩៣ ។

[28] *សូមអាន* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ១៥២ ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-៧៥), ឯកសារលេខ D427/1/30, ថ្ងៃទី១១ មេសា ២០១១, កថាខណ្ឌទី ៣៦៨។

គឺជាផលវិបាកមួយនៃការអនុវត្តដែលមានការដាក់កំរិតក្នុងការចូលរួមនៅក្នុង តុលាការនៃទីក្រុងនូរឹមប៊ែរ ដែលវាប្រសើរជាងការមានអត្ថិភាពនៃឧបសគ្គរាំងខាងផ្លូវច្បាប់ចំពោះការកាត់ឲ្យជាប់ទោសបែបដូច្នោះ[29]។

១៦. បន្ទាប់ពីច្បាប់ CCL 10, បទរំលោភសេពសន្ថវៈ ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការអនុម័តនូវលក្ខន្តិកៈសម្រាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) និង រ៉្វាន់ដា (“ICTR”) ។ ទាំងលក្ខន្តិកៈនៃតុលាការ ICTY និងទាំងលក្ខន្តិកៈនៃតុលាការ ICTR បានចែងអំពីការកាត់សេចក្តីនៃ បទរំលោភសេពសន្ថវៈ ស្ថិតនៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[30] ទោះបីជាលិខិតុបករណ៍នីមួយៗ ត្រូវបានធ្វើការអភិវឌ្ឍបន្ថែមទៀតនៅដើមទសវត្សរ៍ទី៩០ ក៏ដោយ ក៏ការរៀបរាប់ឈ្មោះឧក្រិដ្ឋកម្មនានានៅក្នុងលក្ខន្តិកៈទាំងនោះ បានផ្អែកលើមូលដ្ឋាននៃការយល់ដឹងអំពីច្បាប់តាមទម្លាប់អន្តរជាតិ *នៅមុនពេល* មានការអនុម័តលក្ខន្តិកៈទាំងនោះ[31] ។

១៧. ការកាត់សេចក្តីដំបូងក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិលើ បទរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺនៅក្នុង *ករណីរបស់ Akayesu* នៅតុលាការ ICTR ដែលនៅទីនោះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា បទរំលោភសេពសន្ថវៈ ត្រូវបានបង្ហាញភស្តុតាងនៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ ថាជាផ្នែកមួយនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែក[32]។ បន្ទាប់មកទៀត ការរកឃើញនានារបស់តុលាការ ICTR ទាក់ទងនឹងឋានៈនៃ បទរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបញ្ជាក់អះអាងដោយតុលាការ ICTY នៅក្នុង *ករណី*

---

[29] ដូចដែលចៅក្រម Parker បានធ្វើការកត់សំគាល់ថាភស្តុតាងដែលបានបង្ហាញជូននៅតុលាការនូរឹមប៊ែរ គឺមាន “ភាពច្រើនសម្បើមហួសហេតុពេកទាំងបរិមាណនិងខ្លឹមសារលំអិតរបស់វា” ហើយ “ដែលធ្វើឲ្យការវិនិច្ឆ័យនេះមិនអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីពិនិត្យមើលសារឡើងវិញ ឬកត់ត្រានូវឯកសារទាំងមូល ឬភស្តុតាងដោយផ្ទាល់មាត់ដែលត្រូវបានធ្វើការបង្ហាញជូនបាន” ។ *ការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមជនជាតិអាល្លឺម៉ង់សំខាន់ៗ ។ ដំណើរការនីតិវិធីរបស់តុលាការសឹកអន្តរជាតិ ដែលបើកធ្វើនៅទីក្រុងនូរឹមប៊ែរ ប្រទេសអាល្លឺម៉ង់* ផ្នែកទី២២ (ពីថ្ងៃទី២២ សីហា ១៩៤៦ ដល់ថ្ងៃទី១ តុលា ១៩៤៦), ទំព័រទី ៤៥៩ ។

[30] លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICTY ចុះថ្ងៃទី ២៥ ឧសភា ១៩៩៣, វិសោធនកម្មថ្ងៃទី ០៧ កក្កដា ២០០៩, ត្រង់មាត្រា ៥(ឆ)។ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICTR ចុះថ្ងៃទី ០៨ វិច្ឆិកា ១៩៩៤, វិសោធនកម្មថ្ងៃទី ៣១ មករា ២០១០, ត្រង់មាត្រា ៣(ឆ)។

[31] *សូមមើល* របាយការណ៍របស់លោកអគ្គលេខាធិការជូនមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី ៣ ឧសភា ១៩៩៣ ត្រង់កថាខណ្ឌទី ៣៤ (ដែលថ្លែងថា តុលាការ ICTY គួរយកមកអនុវត្តតែវិធានដែលជា “ផ្នែកហួសពីការសង្ស័យនៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិតែប៉ុណ្ណោះបានហើយ”។

[32] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Akayesu* , សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR, ថ្ងៃទី២ កញ្ញា ១៩៩៨, កថាខណ្ឌទី ៦៨៦-៦៨៨ ។

*របស់* Kunarac និងតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន (“SCSL”) នៅក្នុង*ករណីរបស់ Semanza*[33] ។

១៨. សហព្រះរាជអាជ្ញា សន្និដ្ឋានថា វាជាការត្រឹមត្រូវមួយសម្រាប់តុលាការនេះអនុវត្តតាមអង្គនៃយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានគេបង្កើតឡើងសំរាប់បញ្ហានេះ។ ទោះបីជាតុលាការ ICTY, ICTR ឬ SCSL មិនបានកំណត់អត្តសញ្ញាណពីចំណុចជាក់លាក់ដែលត្រង់ចំណុចនោះ បទរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ ដែលស្ថិតនៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិយ៉ាងជាក់ច្បាស់យ៉ាងណាក៏ដោយក៏ វាត្រូវតែបានកើតឡើងនៅពេលភ្លាមៗបន្ទាប់ពីការងើបឡើងពីសង្គ្រាមលោកលើកទី២ ដោយសារតែវាពុំមានការអភិវឌ្ឍន៍ជាដុំកំភួននូវទម្លាប់ ឬយុត្តិសាស្ត្រដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈ នៅក្នុងរវាងឆ្នាំ ១៩៤៥ ដល់ ១៩៩៣ ។

១៩. ការពឹងផ្អែកលើសេចក្តីសម្រេចរបស់តុលាការអន្តរជាតិថា ក្រោយខែមករា ឆ្នាំ១៩៧៩ មិនបំពានលើគោលការណ៍ស្តីពីនីត្យានុកូលភាពទេ។ ផ្ទុយទៅវិញ ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលស្គាល់រួចហើយថា “សេចក្តីសម្រេចទាំងនេះផ្តល់នូវការណែនាំ បកស្រាយទាក់ទងនឹងស្ថានភាពការវិវត្តន៍នៃឧក្រិដ្ឋកម្មមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ”[34]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់នៅក្នុង *ករណីរបស់* Hadžihasanović ថាយុត្តិសាស្ត្រនៃគោលការណ៍ស្តីពីនីត្យានុកូលភាពនៅតុលាការសិទ្ធិមនុស្សអឺរ៉ុបអនុញ្ញាតឲ្យមាន“ការបញ្ជាក់ជាលំដាប់” នៃវិធានស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌតាមរយៈការបកស្រាយតាមផ្លូវតុលាការ និងឆ្លុះបញ្ចាំងការយល់ដឹងថា “វាមិនចាំបាច់ថាធាតុផ្សំបទល្មើសត្រូវបានកំណត់និយមន័យទេ ប៉ុន្តែផ្ទុយទៅវិញថាតើគេបានផ្តល់នូវការរៀបរាប់ទូទៅអំពីការប្រព្រឹត្តិដែលបានហាមឃាត់នោះដែរឬទេ”[35] ។

---

[33] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Kunarac,* សាលក្រម, សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ថ្ងៃទី២២ កុម្ភៈ ២០០១, កថាខណ្ឌទី ៤៣៦-៤៦៤ ។ *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Semanza,* សាលក្រម និងការផ្តន្ទាទោស, សំណុំរឿងលេខ ICTR-97-20-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR, ថ្ងៃទី១៥ ឧសភា ២០០៣, កថាខណ្ឌទី ៤៧៩ ។

[34] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌទី ៣៤ ។ *សូមមើលផងដែរ, ដដែល,* កថាខណ្ឌទី ២៩០ (“គោលការណ៍នីត្យានុកូលភាពមិនបានហាមឃាត់អង្គជំនុំជម្រះ ក្នុងការយោងទៅលើច្បាប់ទំនៀមទម្លាប់ដែលពុំមានសរសេរជាលាយលក្ខណ៍អក្សរ ឬការសម្រេចណាមួយធ្វើឡើងតាមរយៈដំណើរ ការនៃការបកស្រាយ និងការស្រាយបំភ្លឺចំពោះធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយនោះទេ”) ។

[35] *រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និងគូកន,* សេចក្តីសម្រេចលើការតវ៉ារួមចំពោះយុត្តាធិការ, អង្គជំនុំជម្រះសាលាដំបូង ICTY, សំណុំរឿងលេខ IT-01-47-PT, ថ្ងៃទី២៥ កក្កដា ២០០៣ [បន្ទាប់ទៅនេះហៅថា “សាលក្រមលើករណីរបស់ *Hadžihasanović*”, កថាខណ្ឌទី ៥៨ ។

២០. វាមានន័យក្នុងការដែលអនុញ្ញាតឲ្យមានការបំភ្លឺពីបទដ្ឋាននានាជាលំដាប់ តាមរយៈការបកស្រាយតាមផ្លូវច្បាប់ ដោយពិចារណាពីចរិតលក្ខណៈនៃប្រព័ន្ធច្បាប់អន្តរជាតិ កាលណាបទដ្ឋានច្បាប់ជាញឹកញាប់មិនធ្លាប់ត្រូវបានធ្វើជាក្រមច្បាស់លាស់ ចែងជាលក្ខខណ្ឌ និងជាធាតុផ្សំឲ្យបានចំៗ[36]។ តាមការពិត ច្បាប់អន្តរជាតិមិនមែនជាស្នាដៃនៃលក្ខន្តិកៈសម្រាប់មូលហេតុសាមញ្ញមួយដែលថា វានៅមិនទាន់មានប្រភពច្បាប់នៅក្នុងពិភពលោកនេះ ដែលត្រូវបានផ្តល់អំណាចឲ្យអនុវត្តនូវលក្ខន្តិកៈជាសាកលនៅឡើយទេ។ ដូច្នេះ វាជាការចាំបាច់ណាស់ត្រូវតែបានបំភ្លឺតាមរយៈប្រភពផ្សេងៗដូចជាសេចក្តីសម្រេចនានារបស់តុលាការ ។

២១. ដោយសារមិនមានការរីកចំរើនដែលពាក់ព័ន្ធទៅនឹងច្បាប់តាមទម្លាប់អន្តរជាតិទាក់ទងទៅនឹង បទរំលោភសេពសន្ថវៈ ក្នុងអំឡុងចន្លោះពេលយុត្តាធិការរបស់ អវតក ហើយនិងតុលាការពិសេសនានានោះ ការរកឃើញរបស់ អវតក ដែលថា បទរំលោភសេពសន្ថវៈ មិនមែនជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងឆ្នាំ ១៩៧៥-៧៩ គឺន័យថា ការរកឃើញរបស់តុលាការពិសេសនានា ថាបទរំលោភសេពសន្ថវៈ គឺជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ គឺជាការខុសឆ្គង។ ពិតមែនហើយ អវតក មិនជាប់កាតព្វកិច្ចដោយសារតែសេចក្តីសម្រេចនានារបស់តុលាការផ្សេងៗ ទៀតនោះឡើយ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ដោយសារតែភាពជាប់លាប់ នៃការរកឃើញរបស់តុលាការអន្តរជាតិដទៃទៀត និងគ្មានភាពសមស្របក្នុងការងាកចេញពីការរកឃើញទាំងនេះនោះ សេចក្តីសម្រេចនានាដែលបានរៀបរាប់នៅខាងលើនេះ គួរត្រូវបានភ្ជាប់ទៅនឹងទស្សនៈមួយ

[36] Telford Taylor បានប្រៀបធៀបឋានៈនៃច្បាប់អន្តរជាតិសព្វថ្ងៃនេះទៅនឹងឋានៈនៃប្រព័ន្ធច្បាប់អង់គ្លេ-សាក់សុងកាលពីរាប់សតវត្សរ៍កន្លងមកហើយៗបានដាស់តឿនថា៖ "បើយើងច្រានចោលច្បាប់អន្តរជាតិ វៀរលែងតែវាត្រូវបានតំណាងនៅក្នុងក្រម និងលក្ខន្តិកៈនានា, ដោយមាន *the paraphernalia* ទាំងអស់នៃប្រព័ន្ធយុត្តិធម៌ទំនើប, យើងមិនដែលរកឃើញវាទាល់តែសោះ ព្រោះវាមិនអាចមានអត្ថិភាពនៅក្នុងទម្រង់នេះដោយពុំមានអង្គការនយោបាយពិភពលោកមួយដែលមានការលូតលាស់ខ្ពង់ខ្ពស់ស្របគ្នាបាននោះទេ ។ ហើយតាមពិតទៅ វាគឺពិតជាកើតមកពីដំណើរការនៃការអនុវត្តច្បាប់ដែលស្ថាប័ននយោបាយនានាបានបង្កើតឡើង"។ Telford Taylor, របាយការណ៍ផ្តាច់ព្រ័តជូនទៅលេខាកងទ័ពស្តីពីការកាត់សេចក្តីលើឧក្រិដ្ឋកម្មសង្គ្រាមនៅ NUERNBERG នៅក្រោមច្បាប់ត្រួតពិនិត្យក្រុមប្រឹក្សាលេខ១០ ត្រង់ទំព័រ ២២១ (១៩៤៧)។ *សូមមើលផងដែរ,* សាលក្រមរបស់សាលាដំបូង ICTY, ករណី រដ្ឋអាជ្ញា ទល់នឹង *Delalic,* សំណុំរឿងលេខ IT-96-21-T, ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៨ កថាខណ្ឌទី ៤០៥ (ដោយកត់សម្គាល់ថា ការអនុវត្ត និងបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព អាចផ្សេងគ្នារវាងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាមួយនឹងប្រព័ន្ធជាតិ ហើយថាគោលបំណងនៃគោលការណ៍នីត្យានុកូលភាពដូចដែលបានអនុវត្តនៅក្នុងប្រព័ន្ធអន្តរជាតិ "ទំនងជាខុសគ្នាក្នុង គោលបំណងដ៏ជាក់ច្បាស់នៃការរក្សាតុល្យភាពរវាងការរក្សានូវយុត្តិធម៌និងភាពត្រឹមត្រូវចំពោះជនជាប់ចោទ ជាមួយនឹងការពិចារណាពីការ រក្សាទុកនូវសណ្តាប់ធ្នាប់ពិភពលោក") ។

ក្នុងការលើកស្ទួយនូវភាពត្រឹមត្រូវ និងការចៀសវាងដែលមិនចាំបាច់នូវភាពមិនច្បាស់លាស់នៅក្នុងច្បាប់[37]។

## ខ. ជនចាប់ចោទ អាចព្យាករណ៍ទុកជាមុនបាន និងអាចរកបានថា នឹងមានការកាត់សេចក្តីពីអំពើរំលោភសេពសន្ថវៈដាច់ដោយឡែក នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

២២. គោលការណ៍ស្តីពីនីត្យានុកូលភាព ធ្លាប់ត្រូវបានបកស្រាយដើម្បីតម្រូវថា ច្បាប់ដែលចែងពីការចោទប្រកាន់លើបុគ្គលម្នាក់ពីបទឧក្រិដ្ឋណាមួយត្រូវតែ “ជាទង្វើដែលគេប្រមើលមើលឃើញច្បាស់ថាជាបទឧក្រិដ្ឋ ហើយច្បាប់ដែលចែងអំពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះ ត្រូវតែដឹងដោយជនជាប់ចោទនៅក្នុងកាលៈទេសៈនោះ”[38]។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ទាំងភាពដែលអាចព្យាករណ៍ទុកជាមុនបាន និងទាំងភាពដែលអាចរកបាននៃបទដ្ឋាននេះ គឺមានលក្ខណៈសមស្របពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពី បទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មដាច់ដោយឡែក នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអនុលោមតាមមាត្រា៥ នៃច្បាប់ អវតក។

២៣. ពាក់ព័ន្ធទៅនឹង លក្ខខណ្ឌតម្រូវនៃភាពដែលអាចព្យាករណ៍ទុកជាមុនបាន អង្គបុរេជំនុំជម្រះនៃអវតក ធ្លាប់បានរកឃើញថា “ជនត្រូវចោទត្រូវតែអាចបង្ហាញថា អំពើនោះគឺជាអំពើព្រហ្មទណ្ឌនៅក្នុងន័យដែលអាចដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ”[39]។ ដោយការអនុវត្តនូវបទដ្ឋាននេះចំពោះអង្គហេតុបច្ចុប្បន្ននានា សហព្រះរាជអាជ្ញា សន្និដ្ឋានថា ការកំណត់ឲ្យមាន បទរំលោភសេពសន្ថវៈ នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ គឺត្រូវបានបង្កើតឡើងយ៉ាងគ្រប់គ្រាន់នៅឆ្នាំ១៩៧៥ ដែលដូច្នោះហើយ ជនចាប់ចោទគួរតែអាចយល់ដឹងជាមុនបានថាអំពើទាំងឡាយនៃ បទរំលោភសេពសន្ថវៈ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គហេតុពិតដែលថាបទឧក្រិដ្ឋនេះអាចនឹងត្រូវបានធ្វើការចោទប្រកាន់ក្នុងទម្រង់មួយ ដែលមិនសូវជាក់លាក់

---

[37] តុលាការអន្តរជាតិដទៃទៀត ពិចារណាយុត្តិសាស្ត្រអន្តរជាតិពីមុនៗលើបញ្ហានានាស្តីពីច្បាប់តាមទម្លាប់អន្តរជាតិ ថាជាប្រភពអំណាចដែលមានលក្ខណៈបញ្ចុះបញ្ចូល ។ *សូមមើលជាឧទាហរណ៍, រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន,* ដីកាបង្គាប់ និងសេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ស្តីពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ថ្ងៃទី១ មេសា ២០០៤, សំណុំរឿងលេខ 04-16-PT នៃតុលាការ SCSL, កថាខណ្ឌទី ២៤ ។

[38] *សូមមើលជាឧទាហរណ៍* សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២៨-២៩ ។ សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ១០៥-១០៦ ។

[39] សាលដីការបស់ អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី ២០ ឧសភា ២០១០, D97/14/15, កថាខណ្ឌទី ៤៥ ។

ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ គឺមិនទាក់ទងនឹងការវិភាគពីនីត្យានុកូលភាពទេ ព្រោះថាការប្រព្រឹត្តិ ដែលជាប្រធានបទនៃការរំលោភសេពសន្ថវៈនោះ គឺមានលក្ខណៈតែមួយដូចគ្នា ។

២៤. ពាក់ព័ន្ធនឹងវង្វែងនៃភាពដែលអាចរកបាន នៃការសាកល្បងលើគោលការណ៍ស្ដីពីនីត្យានុកូលភាព អង្គបុរេជំនុំជម្រះនៃ អវតក ធ្លាប់បានរកឃើញថា "វាក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែល ផ្អែកលើទំនៀមទម្លាប់ផងដែរ"[40]។ នៅទីនេះ ខណៈដែលមិនមានការចងជាក្រមសាកលនូវ បទ រំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានអត្ថិភាពក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ទេនោះ ព័ត៌មានចាំបាច់ដែលត្រូវឈានដល់សេចក្ដីសន្និដ្ឋានថា បទរំលោភសេពសន្ថវៈ គឺ អាចផ្ដន្ទាទោសបានក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ (ឧទាហរណ៍ ច្បាប់ CCL 10) គឺមានស្រាប់ជាសាធារណៈ និងដែលអាចរកបាន។

២៥. លើសពីនេះ នៅក្នុងវិសាលភាពដែលថាមានភាពមិនច្បាស់លាស់អំពីថាតើ ការរំលោភសេពសន្ថវៈ គឺជាបទឧក្រិដ្ឋ ស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឬយ៉ាងណា។ ដំណោះស្រាយលើភាពមិនច្បាស់លាស់នោះតាមរយៈការកំណត់សម្រេចតាមផ្លូវតុលាការ គឺអាច ព្យាករណ៍ទុកជាមុនបាន[41]។ ដូច្នេះ ទីប្រឹក្សាច្បាប់ដែលមានសមត្ថភាពម្នាក់ ដែលវាយតម្លៃអំពី ស្ថានភាពច្បាប់អន្តរជាតិ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ អាចជូនដំណឹងដល់ជនជាប់ចោទ ឲ្យបានដឹងជាមុនថា បទល្មើសរំលោភសេពសន្ថវៈ អាចត្រូវបានផ្ដន្ទាទោសជា ឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ។ ការណ៍នេះគឺពិត ដោយមានទាក់ទងនឹងចរិតលក្ខណៈជាក់ស្ដែងយ៉ាងច្បាស់នៃ អំពើនានាក្នុង បទរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩។ វាគឺជាការមួយដែលមិនអាចយល់បានទេ ដែលថាអ្នកមានសុភនិច្ឆ័យម្នាក់ បាន ជឿថា អំពើទាំងនេះវាមិនរំលោភទៅនឹងលក្ខខណ្ឌតម្រូវរបស់ច្បាប់ និងភាពសមស្របជាសកលទេ

---

[40] សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្ម ឧក្រិដ្ឋកម្មរួម, ថ្ងៃទី ២០ ឧសភា ២០១០, D97/14/15, កថាខណ្ឌទី ៥៥ ។ *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Milutinović និងគូកន,* សាលដីកា លើញត្តិរបស់ Ojdanic ជំទាស់នឹងបញ្ញាយុត្តាធិការ - សហកម្មឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី២១ ឧសភា ២០០៣ [បន្ទាប់ទៅនេះហៅថា "សាលដីកាលើបញ្ហា JCE របស់*Milutinović*"], កថាខណ្ឌទី ៣៧-៣៩ ។

[41] *សូមមើល SW ទល់នឹង* ចក្រភពអង់គ្លេស,ECHR, ថ្ងៃទី២២ វិច្ឆិកា ១៩៩៥, Ser A 335-B, កថាខណ្ឌទី ៣២-៤៣ (ដោយរកឃើញថា ការដកហូតអភ័យឯកសិទ្ធិរបស់ប្ដីចេញពីការចោទប្រកាន់ក្នុងករណីរំលោភសេពសន្ថវៈលើប្រពន្ធរបស់គាត់គឺមានលក្ខណៈ "អាចព្យាករណ៍ទុក ជាមុនបានយ៉ាងសមហេតុសមផល តាមផ្លូវច្បាប់ដ៏សមស្រប" ។

ដូចជាដើម្បីធានាមិនឲ្យមានឧក្រិដ្ឋបទីយកម្មតាមរយៈមធ្យោបាយ នៃបទល្មើសដាច់ពីគ្នាមួយជាដើម[42]។ ស្រដៀងគ្នានេះដែរ ខណៈដែលបទរំលោភសេពសន្ថវៈនៅក្រោមច្បាប់របស់ប្រទេសកម្ពុជា មិនមានធាតុផ្សំ គ្រប់គ្រាន់ដែលមានលក្ខណៈរួមគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អត្ថិភាពនៃ បទរំលោភសេពសន្ថវៈ ដែលជាបទឧក្រិដ្ឋមួយនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[43] បានគាំទ្រដល់ទស្សនៈមួយដែលថា បុគ្គលដែលមានការគិតគូរដ៏សមហេតុសមផលម្នាក់ មុខជានឹងឃើញតាមគុណតម្លៃពីលទ្ធភាពមួយដែលថា ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ អាចនឹងត្រូវភ្ជាប់ទៅនឹងអំពើទាំងឡាយនៃ បទរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ។

## គ. ការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺស្របគ្នាទៅនឹងគោលបំណងនៃគោលការណ៍ស្តីពីនីត្យានុកូលភាព

២៦. គោលការណ៍ស្តីពីនីត្យានុកូលភាព ស្វែងរកនូវការទប់ស្កាត់ដើម្បីកុំឲ្យឧក្រិដ្ឋបទីយកម្មនៃបទល្មើសមានជាប្រតិសកម្ម និងការចោទប្រកាន់នានាដែលជាមូលដ្ឋានមិនត្រឹមត្រូវចំពោះជនជាប់ចោទ។ ទោះជាយ៉ាងដូច្នេះក៏ដោយ គោលការណ៍ស្តីពីនីត្យានុកូលភាពមិនតម្រូវឲ្យមានបទឧក្រិដ្ឋមួយ ដែលត្រូវបានលុបចោល ខណៈដែលមានខចែងចំៗ និងដូចគ្នាបេះបិទ ដែលក្នុងនោះ ក្រោយមកវាត្រូវបានគេធ្វើការចោទប្រកាន់។ ផ្ទុយទៅវិញ ដូចដែលតុលាការ ICTY បានថ្លែងនៅក្នុង *ករណីរដ្ឋអាជ្ញា ទល់នឹង* Hadzihasanovic, គោលការណ៍ស្តីពីនីត្យានុកូលភាព "ត្រូវបានបំពេញ បើគេអាចផ្តន្ទាទោសលើទង្វើឧក្រិដ្ឋជាមូលដ្ឋានបែបដូច្នោះ ដោយមិនគិតពីរបៀបដែលគេបង្កើតបទចោទជាក់ស្តែងតាមច្បាប់ជាក់លាក់ណាមួយនោះទេ"[44]។

[42] សាលដីកាលើបញ្ហាJCEរបស់*Milutinović*, កថាខណ្ឌទី៤២ (ដោយថ្លែងថា"ទោះបីជាភាពខ្វះសីលធម៌ ឬចរិតដ៏រន្ធត់នៃអំពើមួយមិនមែនជាកត្តាគ្រប់គ្រាន់ដើម្បីធានាពីការធ្វើពិរុទ្ធកម្មនៅក្រោមច្បាប់តាមទម្លាប់អន្តរជាតិក៏ដោយ ក៏តាមពិតវាអាចដើរតួនាទីមួយនៅក្នុងប្រការនោះក្នុងទំហំមួយដែលថាវាអាចនឹងបដិសេធលើការអះអាងណាមួយដោយមេធាវីការពារក្តី ដែលថាវាមិនបានដឹងពីចរិតលក្ខណៈឧក្រិដ្ឋនៃអំពើនោះ")។

[43] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦, មាត្រា ៤៤៣។

[44] សេចក្តីសម្រេចលើបញ្ហាយុត្តាធិការរបស់ *Hadžihasanović*", កថាខណ្ឌទី ១៦៥ ។ *សូមមើលផងដែរ* សាលដីកាលើបញ្ហា JCE របស់ *Milutinović*, កថាខណ្ឌទី ៣៨ (ដោយបានទទួលស្គាល់ថាគោលការណ៍ស្តីពីនីត្យានុកូលភាពមិនរារាំងដល់ការរីកចម្រើនជាលំដាប់នៃច្បាប់នោះទេ ដរាបណាការរីកចម្រើននោះឋិតនៅក្នុង "កំរិតដ៏សមហេតុសមផលនៃភាពច្បាស់លាស់ដែលអាចទទួលយកបាន") ។

២៧. ដូច្នោះហើយ សំនួរពាក់ព័ន្ធនៅ អវតក គឺថាតើ *ការប្រព្រឹត្តិដែលឈានដល់ការរំលោភសេពសន្ថវៈ* អាចត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ តាមបែប ដូចជាត្រូវបានព្យាករណ៍ទុកជាមុនបានថា ជនជាប់ចោទអាចនឹងត្រូវបានផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមានមូលដ្ឋាននៅលើការប្រព្រឹត្តិនោះដែរឬទេ។ បើនិយាយឱ្យខ្លីបញ្ហា គឺនៅលើអង្គសេចក្តី មិនមែននៅលើការដាក់ឈ្មោះនោះទេ។

២៨. នៅក្នុងតួយ៉ាងបច្ចុប្បន្ននេះ វាពុំមានភាពមិនត្រឹមត្រូវភ្ជាប់ជាមួយនឹងការចោទប្រកាន់ពី បទរំលោភសេពសន្ថវៈតាមបែបដូច្នេះ ជាជាងតាមបែបអនុក្រុមក្នុងប្រភេទ“អំពើអមនុស្សធម៌ផ្សេងៗទៀត”។ តាមពិតទៅ បើសិនជាមានភាពច្បាស់លាស់ណាមួយបានកើនឡើងដោយរួមផ្សំជាមួយនឹងការចោទប្រកាន់ពី បទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានរៀបរាប់យ៉ាងជាក់លាក់មកនេះ នោះជនជាប់ចោទ មុខជានឹងត្រូវបានប្រាប់ដំណឹងជាមុនយ៉ាងទូលំទូលាយអំពីករណីនេះ ដែលពួកគាត់ចាំបាច់ត្រូវឆ្លើយ ហើយបើមិនដូច្នោះទេ ពេលដល់វេនត្រូវធ្វើការឆ្លើយតបនឹងមានភាពជាក់លាក់មែនទែនជាងករណីនេះទៅទៀត។ លើសពីនេះទៀត ការចោទប្រកាន់លើជនជាប់ចោទពី បទរំលោភសេពសន្ថវៈ តាមបែបតែឯងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងតាមបែបបុត្រសម្ព័ន្ធនៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត” នឹងមានប្រយោជន៍បន្ទាប់បន្សំនៃការធ្វើវិភាគទានដល់កំណត់ត្រាប្រវត្តិសាស្ត្រនៃករណីនេះ តាមរយៈការចាត់ឱ្យមានការចោទ ប្រកាន់នានាតាមរបៀបមួយដែលមានលក្ខណៈច្បាស់លាស់ជាង និងងាយយល់ជាងចំពោះ សមាជិកនានានៃសាធារណជនទូទៅ។

### ឃ. អង្គហេតុនៅក្នុងដីកាដំណោះស្រាយផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការសម្រេចថា បទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតឡើង

២៩. ដីកាដំណោះស្រាយបានកំណត់អំពីអង្គហេតុនានាដែលថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះ បទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានកើតឡើងក្នុងរយៈកាលដែលពាក់ព័ន្ធ ។

៣០. តាមការកត់សំគាល់ជាពិសេស បទរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវ

បានប្រព្រឹត្តឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ ត្រង់ផ្នែកដែលដាក់ចំណងជើងថា "ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍" និងនៅក្រោមជំពូក "ការកត់សំគាល់ឃើញអំពីអង្គហេតុនៃសហកម្មឧក្រិដ្ឋកម្មរួម"[45] និង"ការកត់សំគាល់ឃើញអំពីអង្គហេតុ នៃឧក្រិដ្ឋកម្ម"[46] ទិសដៅមួយក្នុងចំណោមទិសដៅនានារបស់ បកក ក្នុងការបង្ខំឲ្យគូស្រករៀបការជាមួយគ្នាជាក្រុមនៅទូទាំងប្រទេសគឺដើម្បី "ត្រួតត្រាទៅលើអន្តរសកម្មភាពរបស់បុគ្គលម្នាក់ៗ ធ្វើដូច្នេះដើម្បីឲ្យពួកគេត្រូវបានអនុញ្ញាតឲ្យរៀបការនិងមានទំនាក់ទំនងផ្លូវភេទតែទៅតាមគោលនយោបាយរបស់ បកក តែប៉ុណ្ណោះ ។ បកក ក៏មាន "ទិសដៅបង្កើនកំណើនប្រជាជន" ផងដែរ ដូច្នេះអាពាហ៍ពិពាហ៍ដោយបង្ខំ បាននិងកំពុងជាផ្នែកមួយនៃគោលនយោបាយកសាងជាតិកម្ម(ការបន្តពូជ) និងគ្រួសារបដិវត្តន៍មួយដែលបានផ្សព្វផ្សាយ ដោយមន្ត្រីជាន់ខ្ពស់របស់កបប[47] ។ គោលនយោបាយនៃការរៀបការជាក្រុមនេះ ត្រូវបានគេប្រកាសនៅថ្នាក់ខ្ពស់បំផុត[48] ប៉ុន្តែពិធីនេះត្រូវបានចាត់ចែងឡើងយ៉ាងជាក់ស្តែងដោយអាជ្ញាធររដ្ឋបាលមូលដ្ឋាន នៅក្រោមកាលៈទេសៈដោយបង្ខំ[49] ។ មានឧទាហរណ៍ជាច្រើនបង្ហាញថា គូស្រករដែលមានឋានៈដូចគ្នាត្រូវបានផ្គូផ្គងដោយអាជ្ញាធរ ទោះបីជាគេមានភស្តុតាងបង្ហាញថា នៅពេលណាខាងកងទ័ពចង់រៀបការឲ្យទាហានរបស់ខ្លួន -រួមទាំងទាហានពិការផង- ពួកគេនឹងជ្រើសយកស្ត្រីពីតាមភូមិផ្សេងៗក៏ដោយ[50] ។ ជាក់លាក់ជាងនេះដូចបាននិយាយក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា គេមានភស្តុតាងនៅក្នុងសំណុំរឿងបញ្ជាក់ថា នៅក្នុងបណ្តាអង្គភាពទ័ព អាស្រ័យដោយមានការយល់ព្រមពីអង្គការទាហាន បកក ជាញឹកញាប់តែងទទួលបានរង្វាន់លើកទឹកចិត្តសម្រាប់ការរួមចំណែករបស់ពួកគេចំពោះបដិវត្តន៍ តាមរយៈការជ្រើសរើសដៃគូអាពាហ៍ពិពាហ៍ដោយបង្ខំ[51] ។ ជាការបន្ថែម ស្ត្រីចាមក៏ត្រូវបានគេបង្ខំឲ្យរៀបការជាមួយដៃគូមិនមែនជាចាម ផងដែរ[52] ។

---

[45] ដីកាដំណោះស្រាយ, កថាខណ្ឌទី ២១៦-២២០។

[46] ដីកាដំណោះស្រាយ, កថាខណ្ឌទី ៨៤២-៨៦១ ។

[47] ដីកាដំណោះស្រាយ, កថាខណ្ឌទី ២១៧។ សូមអានផងដែរ ដីកាសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៦ សីហា២០១០ ឯកសារលេខ D390 កថាខណ្ឌ៣០៧៨-៣០៩, ៣១២-៣១៥["ដីកាសន្និដ្ឋានស្ថាពរ"] ។

[48] ដីកាដំណោះស្រាយ, កថាខណ្ឌទី ៨៤៥ ។

[49] ដីកាដំណោះស្រាយ, កថាខណ្ឌទី ៨៤៦, ៨៤៩-៨៥០។ *សូមអានផងដែរ* ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣១០-៣១១, ៣២០ ។

[50] ដីកាដំណោះស្រាយ, កថាខណ្ឌទី ៨៤៨ ។ ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣០៩ ។

[51] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣០៩ ។

[52] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣១៧, ១៤៥១ ។

៣១. បន្ទាប់ពីពិធីរៀបការរួច គេមានភស្តុតាងបញ្ជាក់ថា គូស្រករត្រូវនៅជាមួយគ្នាដើម្បីធានាចំពោះការបំពេញបញ្ចប់អាពាហ៍ពិពាហ៍ឲ្យបានពេញលេញ (ការរួមដំណេក) ឬ ត្រូវជួបគ្នាលើកក្រោយទៀតជាទៀងទាត់ ។ ការប្រឈមខាងផ្លូវភេទដោយបង្ខំជាលើកដំបូងទាំងនោះ ដែលយ៉ាងហោចណាស់ប្រឆាំងនឹងឆន្ទៈរបស់ដៃគូម្នាក់ក្នុងចំណោមគូភាគីទាំងពីរ ជួនកាលត្រូវបានតាមដាន ឬលួចយកការណ៍ដោយឈ្លប បកក[53] ។ គូស្រករណាដែលមិនព្រមរួមដំណេកជាមួយគ្នា នឹងត្រូវបានចាប់ខ្លួនវាយដំ ឬសម្លាប់ចោល[54] ។ គឺក្នុងបរិបទនេះហើយដែលការរំលោភសេពសន្ថវៈរាប់ពាន់ ត្រូវបានគេលើកទឹកចិត្ត និងត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃគោលនយោបាយនៃការរៀបការ និងជាតិកម្ម (ការបន្តពូជ)ដោយបង្ខំនៅទូទាំងប្រទេស និងជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ និងដ៏ទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិល[55] ។ ការមានផ្ទៃពោះដោយបង្ខំជាលទ្ធផលកើតចេញពីការរំលោភសេពសន្ថវៈទាំងនេះ[56] ។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានរំលឹកឡើងវិញក្នុងដីកាដំណោះស្រាយរបស់ខ្លួន ឧក្រិដ្ឋកម្មនៃបទរំលោភសេពសន្ថវៈក្នុងបរិបទនៃចំណងអាពាហ៍ពិពាហ៍ គឺជាបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋនានាដែលបានប្រើដោយមេដឹកនាំ បកក ដើម្បីអនុវត្តគោលបំណងរួមរបស់ពួកខ្លួន[57] ។

៣២. អង្គហេតុជាក់ស្តែងនានាដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ក៏កំណត់ឲ្យឃើញផងដែរអំពីការរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យក្នុងកាលៈទេសៈខុសគ្នាជាច្រើនដែលស្ថិតខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ ជាការគួឲ្យកត់សំគាល់គឺនៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានា[58] ។ មិនដូចការរំលោភសេពសន្ថវៈក្នុងបរិបទនៃចំណងអាពាហ៍ពិពាហ៍ដោយបង្ខំទេ បទឧក្រិដ្ឋជាក់លាក់មួយនេះត្រូវបានប្រព្រឹត្តឡើងដោយមិន

[53] ដីកាដំណោះស្រាយ, កថាខណ្ឌទី ២២០, ៨៥៨-៨៦០។ ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣២១-៣២២ ។

[54] ដីកាដំណោះស្រាយ, កថាខណ្ឌទី ១៤៣២។ ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌទី៣២១, ១៤៤៧ ។

[55] ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤៣០-១៤៣៣ ។ ដីកាសន្និដ្ឋានស្ថាពរ, កថាខ័ណ្ឌទី១៤៤៥ ។

[56] ដីកាសន្និដ្ឋានស្ថាពរ, កថាខ័ណ្ឌទី៣២២ ។ *សូមអាន* ផងដែរ ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី៨៦០ ។

[57] ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤៣២ ។

[58] ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី៤៥៧-៤៥៩ (ស-២១), ៤៨២ (សង់), ៥០៤ (ក្រាំង តាចាន់), ៥៤៩ (ព្រៃដំរីស្រុត), ៥៧៨ (ភូមិភាគឧត្តម), ៦៦២ (វត្តធ្លក), ៧៨៥ (ស្ត្រីចាម នៅក្រូចឆ្មារ) និង ១៤២៦ ។ *សូមអាន* ផងដែរ ដីកាសន្និដ្ឋានស្ថាពរ, កថាខ័ណ្ឌទី៣៨២, ៤៧០, ៤៨៥, ៥៨០, ៦២៨, ៦៥៦, ៧៦៨ និង ១៤៤៩ ។

មានការដាក់ទណ្ឌកម្មជាក់ស្តែងដោយ បកក ទេ ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឧក្រិដ្ឋកម្មបែបនេះ គឺជាផលវិបាកដែលគេអាចទាយទុកជាមុនបានអំពីសហកម្មឧក្រិដ្ឋកម្មរួម ដោយហេតុថា វាមានការពាក់ព័ន្ធនឹងការបាត់បង់ភាពជាមនុស្ស ការធ្វើទារុណកម្ម និងការបន្ទាបបន្ថោកដោយគិតទុកជាមុនចំពោះមនុស្សដែលគេហៅថា "ពួកសមាសសភាពមិនល្អ"។

## ៦. សេចក្តីសន្និដ្ឋាន

៣៣. សេចក្តីដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីលើអង្គហេតុនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានជាប់ទាក់ទងទៅនឹងការប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ថាជា បទរំលោភសេពសន្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រសើរជាងថាជា បទ អំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |